មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សារណាសង្ខេបទាក់ទងនឹងលោក វន់ ពៅ និង ប្រាំពីរអ្នកផ្សេងទៀត ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៩៣៦
# ដាក់ជូនសាលាឧទ្ធរណ៍ ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ (“អង្គការ”) ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”)។ ម.ស.ម.ក បានវិភាគទៅលើច្បាប់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធទៅនឹងសំណុំរឿងរបស់លោក **វន់ ពៅ និងជនជាប់ចោទប្រាំពីនាក់ផ្សេងទៀត**។ ម.ស.ម.ក សូមគោរពផ្តល់ជូនសារណានេះដល់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា នាឱកាសបើកសវនាការលើសំណុំរឿងនេះ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦។

## សាចតារ និងកាលប្បវត្តិ

ជនជាប់ចោទដែលមាននៅក្នុងនីតិវិធីនេះមានដូចខាងក្រោម ៖

១ លោក វន់ ពៅ អាយុ ៣៩ ឆ្នាំ
២ លោក ថេង សាវឿន អាយុ ២៤ ឆ្នាំ
៣ លោក ចាន់ ពុទ្ធិស័ក្តិ អាយុ ៤០ ឆ្នាំ
៤ លោក សុគុណ សម្បត្តិពិសិដ្ឋ អាយុ ៣១ ឆ្នាំ
៥ លោក ឈឹម ជឿន អាយុ ២៧ ឆ្នាំ
៦ លោក យ៉ុង សំអន អាយុ ៣១ ឆ្នាំ
៧ លោក លន សាន អាយុ ២០ ឆ្នាំ
៨ លោក តេង ចន្នី ហៅ តេង ចន្ទី អាយុ២១ឆ្នាំ

តទៅ ជនជាប់ចោទទាំងដប់នាក់នឹងហៅរួមគ្នាថា “ជនជាប់ចោទ”។

សំណុំរឿងបច្ចុប្បន្នជាប់ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន និងចោទប្រកាន់បទឧក្រិដ្ឋ នៃជនជាប់ចោទ ជាប់ទាក់ទងនឹងការតវ៉ាដោយកម្មកររោងចក្រកាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ។

សវនាកាត្រូវបានធ្វើឡើងនៅថ្ងៃទី២៥ ខែមេសា ថ្ងៃទី៦ ខែឧសភា និងទី ២០-២២ ខែឧសភា ឆ្នាំ២០១៤ នៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទទាំងអស់ត្រូវបានតុលាការចោទប្រកាន់ដំបូងពីបទ "ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស" និងបទ "ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស" តាមមាត្រា ២១៨ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។ នៅដំណាក់កាលស៊ើបអង្កេត ជនជាប់ចោទបួននាក់ ជាអ្នកការពារសិទ្ធិមនុស្ស គឺលោក វន់ ពៅ លោក ថេង សាវឿន លោក ចាន់ ពុទ្ធិស័ក្តិ និងលោក សុគុណ សម្បត្តិពិសិដ្ឋ ត្រូវបានផ្លូវបទចោទទៅជាបទ "ចេតនាញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ" តាមមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ ការចោទប្រកាន់ទៅលើជនជាប់ចោទទាំង ៤កាន់តែមានស្ថានទម្ងន់ថែមទៀតនៅក្នុងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ហើយបានប្តូរបទចោទទៅជា "អ្នកផ្តើមគំនិត" ឲ្យប្រព្រឹត្តអំពើហិង្សាដែលទទួលទោសដូចគ្នានឹងជនដៃដល់អនុលោមតាមមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមដែលប្រកាសកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ បានរកឃើញថាជនជាប់ចោទទាំងជប់សុទ្ធតែមានពិរុទ្ធភាព និងត្រូវដាក់ទោសពន្ធនាគាររយៈពេលចាប់ពី ២ឆ្នាំកន្លះដល់ ៤ឆ្នាំកន្លះ។ សំណុំរឿងនេះត្រូវបានប្តឹងទៅសាលាឧទ្ធរណ៍នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤ ។

ដោយបានតាមដានលើករណីនេះ ម.ស.ម.ក សូមជម្រាបថា សវនាការនោះពុំបានអនុលោមទៅតាមច្បាប់អន្តរជាតិ ឬច្បាប់ជាតិនោះទេ ហើយជនជាប់ចោទនៅក្នុងសំណុំរឿងនោះត្រូវបានបដិសេធនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## ក្របខ័ណ្ឌច្បាប់ និងបញ្ហានានា

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បង្កើតបាននូវធាតុផ្សំដ៏សំខាន់នៃនីតិរដ្ឋ និងជាការរៀបចំប្រព័ន្ធយុត្តិធម៌ដ៏ត្រឹមត្រូវ។ សិទ្ធិនេះរួមផ្គុំនូវសិទ្ធិបុគ្គលជាច្រើន ដែលគ្របដណ្តប់នូវនីតិវិធីច្បាប់ទាំងស្រុង ចាប់តាំងពីដំណាក់កាលចាប់ខ្លួនជនជាប់ចោទជាលើកដំបូង រហូតដល់ការប្តឹងសាទុក្ខចុងក្រោយ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសិទ្ធិមូលដ្ឋានរបស់បុគ្គលគ្រប់រូបដោយមានការទទួលស្គាល់ជាសកល មានចែងក្នុងឋានានុក្រមខ្ពស់បំផុតនៃច្បាប់អន្តរជាតិតាមរយៈសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើ ក.អ.ស.ព.ន នៅក្នុងឆ្នាំ១៩៩២ ហើយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") [1] បានចែងពីកាតព្វកិច្ចក្នុងការគោរពសិទ្ធិ

[1] មាត្រា ៣១ រដ្ឋធម្មនុញ្ញកម្ពុជា ៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយណាដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ អាចរកបានតាមរយៈ៖ http://bit.ly/1hcJqYV។

មនុស្សនៅក្នុងច្បាប់ជាតិ និងគោលនយោបាយ។ ដូច្នេះ បទដ្ឋានស្តីពីសិទ្ធិមនុស្សអន្តរជាតិ រួមទាំងបទប្បញ្ញត្តិនៃ ក.អ.ស.ព.ន ត្រូវអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា ដូចបានបញ្ជាក់តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅក្នុងឆ្នាំ២០០៧។[2]

ស.ស.ស.ម[3] និង ក.អ.ស.ព.ន[4] ធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ តាមរយៈសាលាជម្រះក្តីដោយឯករាជ្យ និងមិនលំអៀង។ ក.អ.ស.ព.ន បង្កើតបន្ថែមនូវទស្សនៈនៃការជំនុំជម្រះដោយយុត្តិធម៌ដែលបានបញ្ចូលនូវសិទ្ធិ និងគោលការណ៍នានាដូចខាងក្រោម ប៉ុន្តែអាចនៅមានបន្តទៀត ដូចជា ៖

- ជនគ្រប់រូប មានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។[5]
- ជនគ្រប់រូប មានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសវនាការជាសាធារណៈពីសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់។[6]
- ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ជាថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ជននោះ ត្រូវបានរកឃើញដោយច្បាប់។[7]
- ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមាដោយស្មើភាពគ្នាយ៉ាងពេញលេញដូចខាងក្រោម ៖
  - ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។[8]
  - ត្រូវមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។[9]
  - ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួសហេតុ។[10]

---

[2] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេច លេខ ០៩២/០០៣/២០០៧(ថ្ងៃទី១០ ខែកក្កដា ២០០៧)

[3] មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ មាត្រា១០ អាចរកបានតាមរយៈ៖http://bit.ly/1gisTm1។

[4] មហាសន្និបាតអង្គការសហប្រជាជាតិ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ មាត្រា ១៤(១) អាចរកបានតាមរយៈ៖ http://bit.ly/1j1mTd1។

[5] មាត្រា ១៤ (១) ក.អ.ស.ព.ន ។

[6] មាត្រា ១៤ (១) ក.អ.ស.ព.ន ។

[7] មាត្រា ១៤ (៣) ក.អ.ស.ព.ន ។

[8] មាត្រា ១៤ (៣) (ក) ក.អ.ស.ព.ន ។

[9] មាត្រា ១៤ (៣) (ខ) ក.អ.ស.ព.ន ។

[10] មាត្រា ១៤ (៣) (គ) ក.អ.ស.ព.ន ។

- ត្រូវបានការជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារក្តីដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ ឬការផ្តល់មេធាវីការពារក្តីដោយឥតគិតថ្លៃ ប្រសិនបើជននោះពុំមានលទ្ធភាពជួលមេធាវីដោយខ្លួនឯង។[11]
- ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នាសាក្សីដាកបន្ទុក ។[12]
- ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតថ្លៃ បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ។[13]
- មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកមកលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។[14]

**បន្ថែមពីនេះ ស.ស.ស.ម ចែងថា ៖**

- មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញ សុំឲ្យតុលាការឯករាជ្យ និងមិនលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចសលើសិទ្ធិកាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងព្រហ្មទណ្ឌ ។[15]
- ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតថាគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីការពារសិទ្ធិជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ។[16]

ម្យ៉ាងទៀតនៅក្នុងមាត្រា ២២ នៃបញ្ញត្តិអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងអ្នកទោស[17] បានចែងដំណាលគ្នាថា ៖

- នៅគ្រប់ស្ថាប័នទាំងអស់ យ៉ាងហោចណាស់ត្រូវមានមន្ត្រីពេទ្យដែលមានវិជ្ជាជីវៈ ជាអ្នកមានចំណេះដឹងខ្លះៗខាងចិត្តសាស្ត្រ។ សេវាកម្មសុខាភិបាលត្រូវរៀបចំឱ្យមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងរដ្ឋបាលសុខាភិបាលទូទៅរបស់សហគមន៍ ឬថ្នាក់ជាតិ។ គេត្រូវរាប់បញ្ចូលទាំងសេវាកម្មចិត្តសាស្ត្រ ដើម្បីធ្វើឱ្យរោគវិនិច្ឆ័យ ហើយក្នុងករណីដាក់លាក់ ត្រូវព្យាបាលបញ្ហាខុសប្រក្រតីនៃជំងឺផ្លូវចិត្ត។
- អ្នកទោសដែលឈឺ ហើយត្រូវការការព្យាបាលពីគ្រូពេទ្យជំនាញ ត្រូវតែបញ្ជូនទៅកាន់ស្ថាប័ន

---

[11] មាត្រា ១៤ (៣) (ឃ) ក.អ.ស.ព.ន ។

[12] មាត្រា ១៤ (៣) (ង) ក.អ.ស.ព.ន ។

[13] មាត្រា ១៤ (៣) (ច) ក.អ.ស.ព.ន ។

[14] មាត្រា ១៤ (៣) (ឆ) ក.អ.ស.ព.ន ។

[15] មាត្រា ១០ ស.ស.ស.ម ។

[16] មាត្រា ១១(១) ស.ស.ស.ម

[17] គោលការណ៍មូលដ្ឋានសម្រាប់គ្រប់គ្រងអ្នកទោស មហាសន្និបាតរបស់អង្គការសហប្រជាជាតិ ដំណោះស្រាយលេខ៤៥/១១១ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

ជំនាញ ឬទៅមន្ទីរពេទ្យស៊ីវិល។ នៅស្ថាប័នណាដែលមានមន្ទីរពេទ្យជំនួយ សម្ភារៈរួមទាំងថ្នាំសង្កូវ ត្រូវផ្តល់ឲ្យបានសមរម្យ សំរាប់ការថែរក្សា និងការព្យាបាលអ្នកទោសដែលឈឺ ហើយត្រូវមានបុគ្គលិកដែលមានការហ្វឹកហ្វឺនត្រឹមត្រូវ។

សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ក៏ត្រូវបានធានាផងដែរនៅក្នុងរដ្ឋធម្មនុញ្ញ។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងនូវក្របខណ្ឌមូលដ្ឋានសម្រាប់ការជំនុំជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា។ រដ្ឋធម្មនុញ្ញផ្តល់នូវសិទ្ធិដល់ប្រជាពលរដ្ឋខ្មែរ និងការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដោយធានាថា ៖

- ពុំមានការរំលោភបំពានលើរូបរាងកាយរបស់បុគ្គលណាមួយឡើយ។
- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅបាន លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។
- ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬទង្វើណាមួយដែលបន្ថែមទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬទណ្ឌិត ត្រូវបានហាមឃាត់។ ចារី សហចារី និងអ្នកសមគំនិតក្នុងអំពើនេះនឹងត្រូវផ្តន្ទាទោសតាមច្បាប់។
- ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី កាយ ឬផ្លូវចិត្តក្តី មិនត្រូវទទួលយកធ្វើជាភស្តុតាងនៃពិរុទ្ធភាពទេ។
- វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
- ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

ម្យ៉ាងទៀត មាត្រា ៥១ មាត្រា១២៨ មាត្រា ១៣០ មាត្រា១៣២ នៃរដ្ឋធម្មនុញ្ញក៏ចែងផងដែរអំពីការបែងចែកអំណាច ហើយឯករាជ្យភាពនៃតុលាការត្រូវធានាដោយព្រះមហាក្សត្រ។

ដូច្នេះ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានធានានៅកម្ពុជា តាមរយៈបទប្បញ្ញត្តិទូទៅ និងជាក់លាក់ដែលមានចែងនៅក្នុងលិខិតូបករណ៍អន្តរជាតិ និងជាតិជាច្រើន។ ម.ស.ម.ក សង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាខកខានក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការធានានូវការជំនុំជម្រះក្តីដោយយុត្តិធម៌ក្នុងរឿងក្តីនេះ ដែលនឹងត្រូវបញ្ជាក់ក្នុងផ្នែកខាងក្រោម។

**សិទ្ធិទទួលបានសេរីភាព សិទ្ធិទទួលបានការប្រឹក្សាផ្នែកច្បាប់ និងលក្ខខណ្ឌឃុំខ្លួន**

ចាប់តាំងពីការចាប់ខ្លួន ជនជាប់ចោទទាំងនោះត្រូវបានឃុំខ្លួនអស់រយៈពេលប្រាំថ្ងៃដោយពុំមានការប្រាស្រ័យទាក់ទងជាមួយមេធាវី ការទទួលបានការថែទាំសុខភាព ឬជួបក្រុមគ្រួសាររបស់ខ្លួនឡើយ។ អាជ្ញាធរទើបតែបញ្ចេញព័ត៌មាននៅថ្ងៃទី០៧ ខែមករា ថា ជនជាប់ចោទទាំងនោះកំពុងជាប់ឃុំនៅមណ្ឌលកែប្រែម៣ ("ម៣") នៅខេត្តកំពង់ចាម ដែលត្រូវចំណាយពេលធ្វើដំណើរដោយរថយន្តរយៈពេល៦ម៉ោងពីរាជធានីភ្នំពេញ។ បន្ទាប់មកទៀត ជនជាប់ចោទត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នអស់រយៈពេលជាង៤ខែ ហើយសវនាការលើកដំបូងត្រូវបានធ្វើឡើងនៅថ្ងៃទី២៥ ខែមេសា។ ម.ស.ម

.ក កសូមជម្រាបថា *ការឃុំខ្លួនដោយពុំទទួលបានការប្រាស្រ័យទាក់ទង* និងការឃុំខ្លួនរង់ចាំការជំនុំជម្រះក្តីជាទង្វើមិនសមហេតុផល ហើយជាការរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ។

ទី១ មាត្រា៩ (១) នៃ ក.អ.ស.ព.ន ការពារសិទ្ធិមានសេរីភាព និងសន្តិសុខរបស់បុគ្គលណាម្នាក់ រួមទាំងសិទ្ធិធានាការពារមិនឲ្យមានការចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្ត។ ជាងនេះទៅទៀត គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលជាស្ថាប័នទទួលបន្ទុកបកស្រាយបទប្បញ្ញត្តិនៃ ក.អ.ស.ព.ន បានថ្លែងបញ្ជាក់ជាថ្មីនៅក្នុងសេចក្តីអត្ថាធិប្បាយទូទៅរបស់ខ្លួនលេខ ៣៥ ថា *ការឃុំខ្លួនដោយពុំទទួលបានការប្រាស្រ័យទាក់ទង* គឺជាការឃុំខ្លួនដោយពុំទទួលបាននូវការទាក់ទងជាមួយប្រភពខាងក្រៅ ដែលរារាំងមិនឲ្យមានអ្នកតំណាងភ្លាមៗនៅចំពោះមុខចៅក្រម ដែលទាក់ទងនឹងការរំលោភលើមាត្រា៩(៣)នៃ ក.អ.ស.ព.ន។ [18] គណៈកម្មាធិការនេះបានបញ្ជាក់បន្ថែមផងដែរថា អាស្រ័យទៅលើថិរវេលា និងអង្គហេតុផ្សេងៗ *ការឃុំខ្លួនដោយពុំទទួលបានការប្រាស្រ័យទាក់ទង* អាចរំលោភបំពានផងដែរនូវសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញានេះ រួមមាន មាត្រា ៦ មាត្រា ៧ មាត្រា ១០ និងមាត្រា១៤។[19] ការពិត សិទ្ធិរបស់ជនជាប់ឃុំក្នុងការប្រាស្រ័យទាក់ទងជាមួយពិភពខាងក្រៅ និងសិទ្ធិទទួលបានការសួរសុខទុក្ខ ជាកិច្ចការពារមូលដ្ឋានប្រឆាំងទៅនឹងការរំលោភបំពានសិទ្ធិមនុស្ស រួមទាំងការធ្វើទារុណកម្ម កាបំពារបំពាន និងការបាត់ខ្លួនដោយបង្ខំ។ ជាមួយគ្នានេះផងដែរ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មរបស់អង្គការសហប្រជាជាតិ បានស្នើឲ្យមានការផ្តល់ឱកាសដល់អ្នកជាប់ឃុំឃាំងបានជួបជាមួយមេធាវី វេជ្ជបណ្ឌិត និងក្រុមគ្រួសាររបស់ពួកគេចាប់ពីពេលដែលពួកគេត្រូវបាននាំចូលទៅក្នុងមន្ទីរឃុំឃាំង រួមទាំងការឃុំខ្លួននៅជំណាក់កាលនគរបាលមកម្ល៉េះ។ [20] ជនណាដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬដាក់ពន្ធនាគារ មានសិទ្ធិជូនដំណឹង ឬឲ្យអាជ្ញាធរជូនដំណឹងដល់អ្នកណាម្នាក់ដែលនៅខាងក្រៅថា ជនជាប់ចោទត្រូវបានគេនាំយកទៅឃុំនៅមន្ទីរឃុំឃាំង និងប្រាប់ពីទីកន្លែងដែលពួកគេកំពុងឃុំខ្លួនោះផងដែរ។[21] ការឃុំខ្លួនដោយពុំទទួលបានឱកាសជួបជាមួយពិភពខាងក្រៅ *ការឃុំខ្លួនដោយពុំទទួលបានការប្រាស្រ័យទាក់ទង* អាចអនុញ្ញាតឱ្យធ្វើបានតែក្នុងកាលៈទេសៈលើកលែងណាមួយ និងក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។ លក្ខខណ្ឌបែបនេះពុំបានលើកឡើងក្នុងករណីនេះឡើយ។

---

[18] បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី ហើយត្រូវមានវត្តមានក្នុងការអនុវត្តន៍សាលក្រម។

[19] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីអត្ថាធិប្បាយទូទៅលេខ៣៥(មាត្រា៩៖ សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន) លេខ៣៥ មុនដដែល។

[20] គណៈកម្មាធិកាប្រឆាំងទារុណកម្ម ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការអង្កេត៖ សហភាពរុស្ស៊ី ឯកសារ អ.ស.ប គ.ប.ទ/គ/គទ/៤(២០០២)៨ (ខ)។

[21] គណៈកម្មាធិកាប្រឆាំងនឹងទារុណកម្ម សេចក្តីអត្ថាធិប្បាយទូទៅលេខ ២, និង១៣។

ម.ស.ម.ក សង្កេតឃើញដោយក្តីបារម្ភថា ជនជាប់ចោទជាច្រើនបានរាយការណ៍ថា នគរបាលបានវាយដំពួកគេនៅពេលចាប់ខ្លួន។ ក្តីបារម្ភក្រៅពីនោះគឺ ជនជាប់ចោទម្នាក់ត្រូវបាននគរបាលវាយរហូតដល់បាក់ដៃ។ ជនជាប់ចោទរូបនោះបាននិយាយថា របួសនោះទាមទារឲ្យមានការវះកាត់ និងរារាំងមិនឲ្យគាត់ធ្វើការងារអ្វីបាន។ ម.ស.ម.ក សូមជម្រាបថា នេះជាការរំលោភបំពានលើមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ដែលមាត្រានេះហាមប្រាមការប្រើប្រាស់អំពើហិង្សាលើរូបរាងកាយទៅលើជនជាប់ឃុំឃាំង។

ម្យ៉ាងវិញទៀត សិទ្ធិក្នុងការជួបជុំជាមួយក្រុមគ្រួសារ សិទ្ធិជួបជាមួយវេជ្ជបណ្ឌិត និងសិទ្ធិទទួលបានការថែទាំសុខភាពនៅក្នុងមន្ទីរឃុំឃាំងក្នុងដំណាក់កាលនគរបាល និងសិទ្ធិទទួលបានការប្រឹក្សាយោបល់ផ្នែកច្បាប់ភ្លាមៗក៏មានចែងនៅក្នុងកតិកាសញ្ញាប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំផងដែរ ដែលកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ២០១៣[22] និងមានចែងនៅក្នុងគោលការណ៍ដើម្បីការពារជនគ្រប់រូបស្ថិតនៅក្រោមការឃុំខ្លួន ឬដាក់ពន្ធនាគាររបស់ អ.ស.ប ។[23] ការរឹតត្បិត ត្រូវបានអនុញ្ញាតតែក្នុងកាលៈទេសៈចាំបាច់ ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ឬសន្តិសុខ និង សណ្តាប់ធ្នាប់ល្អនៅក្នុងស្ថាប័ននោះប៉ុណ្ណោះ។ [24] គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប បានចែងផងដែរថា ការការពារទៅលើជនជាប់ឃុំឃាំង តម្រូវឲ្យជននោះមានលទ្ធភាពទទួលបានការព្យាបាលពីវិជ្ជបណ្ឌិតជាទាន់ពេលវេលា និងទៀងទាត់។[25] សិទ្ធិទាំងនេះ មិនត្រូវបានគេគោរព ហើយពុំមានលក្ខខណ្ឌនានាប្រើប្រាស់សម្រាប់ធ្វើការរឹតត្បិតដោយស្របច្បាប់ណាមួយត្រូវបានរកឃើញនៅក្នុងរឿងក្តីដែលបានវិភាគនេះឡើយ។

ជនជាប់ចោទមួយចំនួនក្នុងចំណោមពួកគេ ដែលបានរងរបួសដោយសារការវាយដំក្នុងពេលចាប់ខ្លួន ពុំទទួលការព្យាបាលពីវេជ្ជបណ្ឌិត ហើយត្រូវបាននគរបាលសួរចម្លើយ ហើយចម្លើយដែលទទួលបាននោះ ត្រូវបានដាក់បង្ហាញធ្វើជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទទាំងនោះ នៅក្នុងតុលាការ ។ ករណីនេះរំលោភលើមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា "ចម្លើយដែលទទួលបានក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្ត ពុំមានតម្លៃជាភស្តុតាងនោះទេ" ព្រមទាំងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ដែលការពារប្រជាពលរដ្ឋ ប្រឆាំងទៅនឹងចម្លើយសារភាពដែលទទួលបានក្រោមការបង្ខិតបង្ខំ។

តាម ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធី") "ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ"។ ទោះជាយ៉ាងនេះ ក្នុងករណីបន្ទាន់បង្កឲ្យមានគ្រោះថ្នាក់ដល់ជីវិត ឬភាពប្រថុយប្រថាន និងការបាត់ភស្តុតាង ចៅក្រមស៊ើបសួរអាចសាកសួរជនជាប់ចោទដោយមិនចាំបាច់កោះហៅមេធាវីបាន។ ករណីបន្ទាន់ត្រូវសរសេរនៅក្នុងរបាយការណ៍។ នៅក្នុងរឿងក្តីនេះមានការរំលោភលើមាត្រានេះ ដោយចៅក្រមស៊ើបសួរបានសួរចម្លើយជនជាប់ចោទក្នុងថិរវេលា ២៤ម៉ោងនៃការចាប់ខ្លួនជនជាប់ចោទ។ ម្យ៉ាងទៀត ជនជាប់ចោទមិនត្រូវបានគេផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីជួបជាមួយអ្នកប្រឹក្សាផ្នែកច្បាប់របស់ខ្លួន និងរៀបចំវិធីសា

[22] មាត្រា ១៧(២) (ឃ) នៃកតិកាសញ្ញាស្តីពីការបាត់ខ្លួនដោយបង្ខំ។

[23] គោលការណ៍២៤ នៃគោលការណ៍ដើម្បីការពារជនគ្រប់រូបស្ថិតនៅក្រោមការឃុំខ្លួន ឬដាក់ពន្ធនាគាររបស់ អ.ស.ប។

[24] គោលការណ៍១៩ នៃគោលការណ៍ដើម្បីការពារជនគ្រប់រូបស្ថិតនៅក្រោមការឃុំខ្លួន ឬដាក់ពន្ធនាគាររបស់ អ.ស.ប។

[25] សេចក្តីអត្ថាធិប្បាយទូទៅរបស់ គណៈកម្មាធិការសិទ្ធិមនុស្ស លេខ ២០ និង១១។

ស្រ្តីការពារក្ដីនៅមុនពេលការស្នើរចម្លើយរបស់ចៅក្រមស៊ើបសួរ ឬព្រះរាជអាជ្ញានោះទេ ដែលនេះជាការរំលោភលើមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា១៤ (៣) (ខ) នៃ ក.អ.ស.ព.ន។

ម.ស.ម.ក សូមគូសបញ្ជាក់ថា ការឃុំខ្លួនទៅលើជនជាប់ចោទ បានរំលោភបន្ថែមទៅលើមាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងថា *"ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្ដើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឲ្យតែជននេះមានការទាក់ទិននៅក្នុងរឿងក្ដីជាមួយ..."* និងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងដែរថា ការឃុំខ្លួនបណ្ដោះអាសន្ន អាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះជាការចាំបាច់[26] កិច្ចការពារទាំងនោះ មិនត្រូវបានប្រកាន់ខ្ជាប់ខ្ជួននោះទេ។ ក្នុងចំណោមជនជាប់ចោទដែលត្រូវចាប់ខ្លួនទាំងនោះ ត្រូវបានតុលាការបដិសេធសំណើសុំនៅក្រៅឃុំជាច្រើនលើកច្រើនសារ និងនៅបន្តស្ថិតនៅក្នុងពន្ធនាគារចាប់តាំងពីដើមខែមករា ឆ្នាំ ២០១៤ រហូតដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤។ ពួកគេត្រូវបានបដិសេធសិទ្ធិមានសេរីភាពដោយផ្អែកលើហេតុផលថា ពួកគេនឹងបង្ករការគំរាមកំហែងដល់សណ្ដាប់ធ្នាប់សាធារណៈ ដោយពុំបានបង្ហាញភស្ដុតាងគាំទ្រដល់ការអះអាងបែបនេះទេ។

## សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ នៅចំពោះមុខសាលាជម្រះក្ដីដែលឯករាជ្យ និងមិនលំអៀង និងសិទ្ធិត្រូវសន្មត់ថាជាជនគ្មានទោស

ម.ស.ម.ក សង្កេតឃើញថា ចៅក្រមក្នុងសំណុំរឿងនេះមិនបានផ្ដល់ឱ្យជនជាប់ចោទនូវសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ នៅចំពោះសាលាជម្រះក្ដីឯករាជ្យ និងមិនលំអៀងនោះទេ។ ការជំនុំជម្រះក្ដីនេះបង្ហាញពីភាពលំអៀងយ៉ាងខ្លាំង ដោយសារតែចៅក្រមបានរឹតត្បិតដល់ការបង្ហាញភស្ដុតាងរបស់មេធាវីការពារក្ដីជនជាប់ចោទ។ ព្រះរាជអាជ្ញា និងចៅក្រម បានរារាំងមេធាវីការពារក្ដីជនជាប់ចោទ និងជនជាប់ចោទក្នុងសវនាការនោះផ្ទួនៗគ្នា នៅពេលដែលពួកគេព្យាយាមលើកឡើងពីអំពើឃោរឃៅរបស់យោធា និងនគរបាល ខណៈពេលពួកគេព្យាយាមបង្ហាញភស្ដុតាងដែលពាក់ព័ន្ធទៅនឹងការប្រើហិង្សារបស់កងកម្លាំងសន្តិសុខ។ ក្រុមមេធាវីការពារក្ដីជនជាប់ចោទ ត្រូវបានបង្អាក់មិនឱ្យបង្ហាញភស្ដុតាងមួយចំនួន ដូចជា រូបភាពវីដេអូនៃព្រឹត្តិការណ៍ដែលបានកើតឡើងនៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ខណៈពេលដែលចៅក្រម និងព្រះរាជអាជ្ញាបានបង្ហាញភស្ដុតាងថ្មីក្នុងអំឡុងពេលសវនាការជំនុំជម្រះ ដែលពុំមែនជាផ្នែកណាមួយនៃឯកសារសំណុំរឿងដើមឡើយ។ ចៅក្រមបានផលិតវីដេអូដោយខ្លួនឯងដែលពុំមានការពាក់ព័ន្ធនឹងព្រឹត្តិការណ៍កាលពីថ្ងៃទី ២ ខែមករា ឆ្នាំ២០១៤នោះទេ ប៉ុន្តែ បានបង្ហាញយ៉ាងសាមញ្ញអំពីសកម្មភាពដែលជនជាប់ម្នាក់ក្នុងចំណោមជនជាប់ចោទទាំងនោះកំពុងថ្លែងសន្ទរកថាជាសាធារណៈនៅក្នុងឱកាសផ្សេងគ្នា និងពុំមានការពាក់ព័ន្ធគ្នាឡើយ។ ជា

[26] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ៖ ការឃុំខ្លួនបណ្ដោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះ ជាការចាំបាច់ ៖ "១ ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី, ២ ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត, ៣ ដើម្បីរក្សាភស្ដុតាង ឬតម្រុយជាសម្ភារៈ, ៤ ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី, ៥ ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ, ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស"។

ចុងក្រោយ ការជំនុំជម្រះក្តីនោះបានប្រព្រឹត្តទៅដោយមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ និងអវត្តមានរបស់សាក្សី ហើយសេចក្តីថ្លែងការណ៍ជាលាយល័ក្ខអក្សររបស់ពួកគេត្រូវបានក្រឡាបញ្ជីអាននៅក្នុងបន្ទប់សវនាការទៅវិញ ជាចុងក្រោយ មានការរារាំងមិនឲ្យមានការសួរដេញពួកគេដោយក្រុមមេធាវីការពារក្តីជនជាប់ចោទថែមទៀត។

ម.ស.ម.ក សូមជម្រាបជូនថា ចៅក្រមនៅក្នុងសំណុំរឿងនោះពុំឯករាជ្យ និងលំអៀង ដោយរំលោភបំពានលើមាត្រា ១២៨ និង ១២៩ នៃរដ្ឋធម្មនុញ្ញ មាត្រា ១៤ (១) នៃ ក.អ.ស.ព.ន និង មាត្រា ១០ នៃ ស.ស.ស.ម។ ម.ស.ម.ក សូមជម្រាបជូនផងដែរថា ការកាត់ក្តីរបស់ចៅក្រមក្នុងអំឡុងពេលជំនុំជម្រះនោះ បានរំលោភបំពានផងដែរទៅលើមាត្រា ១១ (១) នៃ ស.ស.ស.ម ដែលចែងថា ជនគ្រប់រូបត្រូវបានសន្មត់ថាគ្មានទោស រហូតទាល់តែពិរុទ្ធភាពត្រូវបានរកឃើញ ហើយការបង្ហាញភស្តុតាងជាបន្ទុករបស់ព្រះរាជអាជ្ញា មាត្រា ១៤ (២) នៃ ក.អ.ស.ព.ន ដែលផ្តល់ឲ្យជនជាប់ចោទពីបទព្រហ្មទណ្ឌនូវ *"សិទ្ធិត្រូវបានសន្មតមុនថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់"* ហើយមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា *"ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"*។

ម.ស.ម.ក សង្កេតឃើញថា ក្នុងអំឡុងពេលជំនុំជម្រះក្តី ចៅក្រមបានសួរជនជាប់ចោទទាំងអស់នូវសំនួរដដែលៗថា ហេតុអ្វីបានជាពួកគេត្រូវចាប់ខ្លួន ប្រសិនបើពួកគេមិនធ្វើអ្វីខុសទេនោះ ដូច្នេះស្មើនឹងការចាប់ខ្លួនដោយមានពិរុទ្ធ ជាមួយគ្នានេះជនត្រូវចោទទាំងអស់ស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូច ដែលមានអក្សរថា "ពិរុទ្ធជន" នៅខាងក្រោយខ្នង ដែលជាការធ្វើឱ្យមានការចាប់អារម្មណ៍ថាជនត្រូវចោទនោះត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋរួចទៅហើយ។ ជាងនេះទៅទៀត តំណាងអយ្យការ និងចៅក្រម បានថ្លែងសំដៅអ្នកតវ៉ាថា ជា "ជនអាណាធិបតេយ្យ" និង "ជើងកាង"។ ម.ស.ម.ក សូមគូសបញ្ជាក់ថា ការចាប់ខ្លួនជនណាម្នាក់ មិនចាត់ទុកថាជាជនមានពិរុទ្ធនោះទេ ហើយវត្តមាននៅកន្លែងតវ៉ាមិនបង្ហាញពីពិរុទ្ធភាពនៃបទល្មើសនោះទេ។ ដូច្នេះ ការជំនុំជម្រះក្តីនោះអាចសន្មតបានថាមានការចន្លោះប្រហោង។

ការសន្មត់ជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានបង្ហាញអនុលោមតាមច្បាប់ ដែលជាមូលដ្ឋានដើម្បីការពារសិទ្ធិមនុស្ស ដែលជាបន្ទុករបស់ស្ថាប័នអយ្យការក្នុងការបង្ហាញបទចោទនានា និងធានាថា គ្មានទោសណាមួយអាចត្រូវបានគេសន្មតជាមុននោះទេ រហូតដល់ការចោទប្រកាន់ត្រូវបានបង្ហាញឡើងផុតពីវិមតិសង្ស័យ។[27]

## សិទ្ធិដឹងពីប្រភេទ និងបុព្វហេតុនៃការចោទប្រកាន់ និងភស្តុតាង

ម.ស.ម.ក បានមើលឃើញក្តីបារម្ភមួយទៀត គឺក្នុងអំឡុងពេលជំនុំជម្រះ ព្រះរាជអាជ្ញាបានសម្រេចលើកឡើងនូវបទចោទធ្ងន់ធ្ងរប្រឆាំងនឹងជនជាប់ចោទទាំង៤រូប នៅក្នុងអំឡុងពេលបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ដែលចៅក្រមរកឃើញពីពិរុទ្ធភាពនៃបទចោទនោះ។ ព្រះរាជអាជ្ញារងបានជម្រាបចៅក្រមក្នុងពេលបញ្ចប់សេចក្តីសន្និដ្ឋានថា បទល្មើសដែលចោទប្រកាន់លើជនជាប់ចោទទាំង ៤រូប គួរតែប្តូរពី "បទញុះញង់" ទៅជា "បទសមគំនិត" ពីព្រោះគ្មានភស្តុតាងបង្ហាញថា ពួកគេគ្រាន់តែជាអ្នកអង្កេតមើលការតវ៉ានោះឡើយ។ ម.ស.ម.ក សូមបញ្ជាក់ថា ការសម្រេចប្តូរបទចោទរបស់ព្រះរាជ

[27] សេចក្តីអត្ថាធិប្បាយទូទៅរបស់ គណៈកម្មាធិការសិទ្ធិមនុស្សលេខ ៣២ និង៣០។

អាជ្ញា និងសាលក្រមផ្តន្ទាទោសរបស់ចៅក្រម គឺជាការរំលោភបំពានទៅលើមាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងថា ជនជាប់ចោទត្រូវតែទទួលបានការជូនដំណឹងពីបទចោទ ប្រឆាំងនឹងខ្លួនតាមរយៈប្រធានអង្គជំនុំជម្រះ ។ ទន្ទឹមនឹងនោះ មាត្រា ១៤ (៣) នៃ ក.អ.ស.ព.ន ដែលផ្តល់សិទ្ធិដល់ជនជាប់ចោទក្នុងការទទួលដំណឹងភ្លាមៗពីបទចោទមកលើខ្លួន ដើម្បីអាចរៀបចំការការពារក្តី។ ប្រសិនបើជនជាប់ចោទពុំបានដឹងទេ ពួកគេពុំអាចបកស្រាយអំពីបទចោទប្រកាន់នោះ និងត្រៀមលក្ខណៈការពារក្តីជាមុននោះទេ ដែលនឹងត្រូវបានកាត់ទោសដោយអយុត្តិធម៌។

ជាចុងក្រោយ រឿងក្តីនេះត្រូវបានគេតាមដានដោយសារកង្វះភស្តុតាងពេញលេញក្នុងការភ្ជាប់ជនជាប់ចោទទៅនឹងបទល្មើស។ គ្មានឯកសារ ឬភស្តុតាងជារូបភាពណាមួយ ត្រូវបានតុលាការបង្ហាញឡើង ដែលអាចភ្ជាប់ជនជាប់ចោទទាំងនោះទៅនឹងបទល្មើសទេ។ ជាក់ស្តែង នៅពេលក្រុមមេធាវីការពារក្តីជនជាប់ចោទសាកសួរសាក្សីដាក់បន្ទុក ពួកគេមិនអាចចំណាំជនជាប់ចោទណាម្នាក់ដែលជាអ្នកប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ការសាកសួររបស់តំណាងអយ្យការ និងចៅក្រមបានផ្តោតតែទៅលើវត្តមានរបស់ជនជាប់ជាប់ចោទនៅកន្លែងតវ៉ា អ្វីដែលពួកគេបានឃើញ និងភាពមិនស៊ីសង្វាក់គ្នានៃកំណត់ហេតុក្នុងព្រឹត្តិការណ៍នានា។ សំនួរ និងចម្លើយរបស់ជនជាប់ចោទទាំងនេះ មិនអាចបង្ហាញពីភស្តុតាងដែលបញ្ជាក់ពីពិរុទ្ធភាពនៅក្នុងបទល្មើសដែលបានចោទនោះទេ។ ម.ស.ម.ក កត់សម្គាល់ឃើញថា មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

## សេចក្តីសន្និដ្ឋាន

ចំពោះហេតុផលទាំងអស់ខាងលើ ម.ស.ម.ក សង្កេតឃើញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងដដែលៗ ក្នុងអំឡុងពេលសវនាការលើសំណុំរឿងនេះ។ ម្យ៉ាងវិញទៀត ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញឲ្យឃើញថា ជនជាប់ចោទណាម្នាក់មានពិរុទ្ធភាពជុំវិញបទចោទប្រកាន់ទៅលើពួកគេនោះទេ។ ដូច្នេះហើយ ម.ស.ម.ក សូមស្នើដល់សាលាឧទ្ធរណ៍មេត្តាបដិសេធចោលនូវសេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ និងសម្រេចលើកលែងការចោទប្រកាន់ចំពោះជនជាប់ចោទទាំងនោះ។